នាយកដ្ឋានជលផល

Department of Fisheries

វិទ្យាស្ថានស្រាវជ្រាវនេសាទទឹកសាបកម្ពុជា

Inland Fisheries Research Institute of Cambodia



# ទិដ្ឋភាពនៃការគ្រប់គ្រងនេសាទទឹកសាបកម្ពុជា

បទបង្ហាញចំនួន ១១ នៅក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់នាយកដ្ឋានជលផល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ថ្ងៃទី ២៧ - ២៨ ខែមករា ឆ្នាំ២០០០

# Management Aspects of Cambodia's Freshwater Capture Fisheries

*Eleven presentations given at the Annual Meeting of the Department of Fisheries*
*Ministry of Agriculture, Forestry and Fisheries*
*27 - 28 January 2000*

កម្មវិធីសហការគ្រប់គ្រង និង អភិវឌ្ឍន៍ជលផល គណៈកម្មការទន្លេមេគង្គ/ដានីដា

MRC/DANIDA - Program for Fisheries Management and Development Cooperation

# ទិដ្ឋភាពនៃការគ្រប់គ្រងនេសាទទឹកសាបកម្ពុជា

# Management Aspects of Cambodia's Freshwater Capture Fisheries

នាយកដ្ឋានជលផល

វិទ្យាស្ថានស្រាវជ្រាវនេសាទទឹកសាបកម្ពុជា

**Department of Fisheries**

Inland Fisheries Research Institute of Cambodia

# ទិដ្ឋភាពនៃការគ្រប់គ្រងនេសាទទឹកសាបកម្ពុជា

*បទបង្ហាញចំនួន ១១ នៅក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់នាយកដ្ឋានជលផល*

*ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ*

*ថ្ងៃទី ២៧ - ២៨ ខែមករា ឆ្នាំ២០០០*

# Management Aspects of Cambodia's Freshwater Caputure Fisheries

*Eleven presentations given at the Annual Meeting of the Department of Fisheries*
*Ministry of Agriculture, Forestry and Fisheries*
*27 - 28 January 2000*

កម្មវិធីសហការគ្រប់គ្រង និង អភិវឌ្ឍន៍ជលផល គណៈកម្មការទន្លេមេគង្គ/ដានីដា

**MRC/DANIDA Program for Fisheries Management and Development Cooperation**

# Management Aspects of Cambodia's Freshwater Capture Fisheries

***Eleven presentations given at the Annual Meeting of the Department of Fisheries Ministry of Agriculture, Forestry and Fisheries 27 - 28 January 2000***

Edited by Nicolaas van Zalinge, Nao Thuok and Lieng Sopha, 2000

Published by the **Management of the Freshwater Capture Fisheries of Cambodia Component** of the **Mekong River Commission's Program for Fisheries Management and Development Cooperation** and the **Department of Fisheries of Cambodia**, 186 Norodom Blvd., P.O. Box 582, Phnom Penh, CAMBODIA, with financial assistance from **Danida**.

Suggested citation:
Van Zalinge, N. P., T. Nao and S. Lieng (Eds.), 2000. Management aspects of Cambodia's Freshwater Capture Fisheries. Eleven presentations given at the Annual Meeting of the Department of Fisheries of the Ministry of Agriculture, Forestry and Fisheries, 27 - 28 January 2000. Mekong River Commission and Department of Fisheries, Phnom Penh, Cambodia, 170 p.

The views and opinions expressed in this publication are not necessarily those of the Department of Fisheries and the Mekong River Commission.

*Photo on front cover:*
*Giant dip net or Chhnuok in operation on the Tonle Tauch River in Kampong Cham Province in January 1999.*

# អារម្ភកថា

កំរងអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រនេសាទនេះ បានធ្វើបទបង្ហាញនៅក្នុងឱកាសប្រជុំបូកសរុបសភាពការណ៍វិស័យជលផលប្រចាំឆ្នាំ នៅថ្ងៃទី ២៧ - ២៨ ខែមករា ឆ្នាំ២០០០ របស់នាយកដ្ឋានជលផល។ កំរងអត្ថបទទាំងនេះត្រូវបានកែសំរួលនិងចងក្រងដោយគ្រោងការគ្រប់គ្រងនេសាទទឹកសាប (CCF) នៃកម្មវិធីជលផល របស់គណៈកម្មការទន្លេមេគង្គ (MRC) និងវិទ្យាស្ថានស្រាវជ្រាវនេសាទទឹកសាបកម្ពុជា (IFRIC)។ ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផល ជាគោលបំណងធំបងរបស់នាយកដ្ឋានជលផល។ នាយកដ្ឋាន កំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការបំពេញសេចក្តីត្រូវការត្រីសាច់ សំរាប់ជាសុវត្ថិភាពស្បៀងអាហារ និងតំរូវការកែលំអសេដ្ឋកិច្ចគ្រួសាររបស់ប្រជារាស្ត្រ។ ទន្ទឹមនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ក៏មានតំរូវការអភិរក្សធនធាន ដើម្បីធានាឱ្យមាននិរន្តរភាព ក្នុងការប្រើប្រាស់ផលនេសាទ ឱ្យបានគង់វង្សដល់កូនចៅជំនាន់ក្រោយផងដែរ។

នាយកដ្ឋានជលផលកន្លងមក នៅពុំទាន់មានសមត្ថភាពតាមផ្លូវច្បាប់ពេញលេញក្នុងការដោះស្រាយបញ្ហាសាំញ៉ាំ ដែលកើតមានឡើងក្នុងវិស័យជលផលឱ្យបានល្អប្រសើរទាំងស្រុងនៅឡើយទេ។ ផលវិបាកនៃការអនុវត្តកន្លងមក បានជះឥទ្ធិពលជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ ទៅលើវិស័យជលផលនៅដំណាក់កាលចុងក្រោយនេះ។ លើសពីនេះទៀត ការកើនឡើងនៃតំរូវការត្រីសាច់ និងតំរូវការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម បានបង្កើតឱ្យមានសំពាធអាជីវកម្មយ៉ាងខ្លាំងលើធនធានជលផល។ ជាអកុសល ទីជំរកត្រីក្នុងធម្មជាតិកំពុងទទួលរងការខូចខាតជាបន្តបន្ទាប់ ប្រភេទត្រីខ្លះកំពុងទទួលការគំរាមកំហែង ឬក្លាយជាប្រភេទកំរ។ កង្វះខាតភស្តុតាងវិទ្យាសាស្ត្រ ក៏ជាការលំបាកក្នុងការធ្វើសេចក្តីសំរេចជ្រើសរើសការគ្រប់គ្រងជលផល ឱ្យបានសមស្របដែរ។

អត្ថបទចងក្រងនេះឆ្លុះបញ្ចាំងពីការស្រាវជ្រាវដែលកំពុងដំណើរការទៅមុខ នឹងជួយផ្តល់ពត៌មានគ្រឹះយ៉ាងរឹងមាំ ដល់ការគ្រប់គ្រង និងអភិវឌ្ឍន៍ជលផល តាមវិធីសាស្ត្រសមស្រប។ ទាំងនេះជាលទ្ធផលទទួលបាន តាមរយៈការស្រាវជ្រាវបែបវិទ្យាសាស្ត្រត្រឹមត្រូវ ដោយការខិតខំប្រឹងប្រែងអនុវត្តយ៉ាងហ្មត់ចត់របស់ក្រុមអ្នកស្រាវជ្រាវនៃនាយកដ្ឋានជលផល និងដោយមានជំនួយឧបត្ថម្ភពីគណៈកម្មការទន្លេមេគង្គ។

ក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះចំពោះកម្មវិធីជលផល របស់គណៈកម្មការទន្លេមេគង្គ សំរាប់គ្រប់គ្រងនេសាទទឹកសាបកម្ពុជា និងវិទ្យាស្ថានស្រាវជ្រាវនេសាទទឹកសាបកម្ពុជា គ្រោងការផ្សព្វផ្សាយ និងអភិវឌ្ឍន៍វារីវប្បកម្មជនបទ (READ) និង គ្រោងការវាយតំលៃធនធានជលផលទន្លេមេគង្គ (AMFC) ដែលបានផ្តល់ពត៌មានវិទ្យាសាស្ត្រទាំងនេះ ដល់ការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យជលផល។ ខ្ញុំក៏សូមសំដែងអំណរគុណផងដែរ ចំពោះជំនួយឧបត្ថម្ភរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRCS) និងជំនួយអភិវឌ្ឍន៍អន្តរជាតិ របស់ប្រទេសដាណឺម៉ាក (DANIDA) ដល់នាយកដ្ឋានជលផល ដែលបានផ្តល់ការជួយឧបត្ថម្ភជារៀងរហូតមក។

សូមមេត្តាចូលរួមចំណែកអភិវឌ្ឍន៍ និងថែរក្សាធនធានជលផលឱ្យបានគង់វង្ស!

ណៅ ធួក

ប្រធាននាយកដ្ឋានជលផល

# Preface

The proceedings of the Annual Meeting of the Department of Fisheries held on 27 – 28 January 2000 were edited and compiled by the Mekong River Commission Fisheries Program Component for Management of the Freshwater Capture Fisheries of Cambodia (CCF) and Inland Fisheries Research Institute of Cambodia (IFRIC). Management, conservation and development of fisheries are the main objectives of the Department of Fisheries. The Department is trying its best to fulfill the requirements of the people for fish as food security, and the need for improving the household income of rural people. At the same time there is also a need to conserve resources for sustainable utilization by the next generation.

So far, the Department of Fisheries still has insufficient legal capacity to solve perfectly all the complex problems occurring in the fisheries sector. The consequences of past management practices have a serious negative impact on fisheries at a later stage. In addition, the increasing demand for fish and the need for economic development heighten the pressure to exploit the fisheries resources. Unfortunately, natural fish habitats are gradually being degraded and some fish species are under threat or are becoming rare. There is still a lack of scientific evidence, which makes it hard to decide on the options for appropriate management of the fisheries.

These proceedings are a reflection of the on-going research that is contributing to a strong basis of information for fisheries management and development in the appropriate way. These are the results achieved through research implemented with strong effort in a scientifically and systematic manner by researchers of the Department of Fisheries together with international assistance from the MRC.

I would like to use this opportunity to express my sincere thanks to the MRC Fisheries Program Component for the Management of Freshwater Capture Fisheries of Cambodia and the Inland Fisheries Research Institute of Cambodia, the Rural Extension for Aquaculture Development Component (READ) and the Assessment of Mekong Fisheries Component (AMFC) for their contribution to support and strengthen fisheries development and management. I would also like to acknowledge the assistance of the Mekong River Commission Secretariat (MRCS) and the Danish International Development Assistance (DANIDA) to the Department of Fisheries.

Let us all help to preserve our fisheries resources!

Nao Thuok
Director
Department of Fisheries

# មាតិកា


| | | |
|---|---|---|
| អារម្ភកថា | | i |
| មាតិកា | | iii |
| លោក ណៅ ធូក<br>លោក នីកូឡាស វ៉ាន់ ហ្សាលីង | កិច្ចខិតខំប្រឹងប្រែងគ្រប់គ្រងនេសាទទឹកសាបកម្ពុជា<br>តើយើងអាចសំរេចបែបណា? | 1 |
| លោក ណាំ សុខលាង | ការវិភាគទិន្នន័យកំរិតធារទឹកហូរនៃទន្លេមេគង្គ | 18 |
| លោក ង៉ោ ប៉េងប៊ុន | ដាយត្រីនៅក្នុងទន្លេសាបនៃរាជធានីភ្នំពេញ និង ខេត្តកណ្ដាល<br>(រួមទាំងការវិភាគឡើងវិញនូវទិន្នន័យដែលបានធ្វើជំរឿននៅឆ្នាំ១៩៩៦-៩៧) | 30 |
| អ្នកស្រី ស្រ៊ន់ ផល្លាវណ្ណ<br>លោក ង៉ោ ប៉េងប៊ុន | ការធ្វើចរាចរនៅរដូវសំរកនៃត្រី ៥ ប្រភេទ ក្នុងទន្លេមេគង្គ ត្រីរៀល *(Henicorhynchus spp.)* ត្រីឆ្កោក *(Cyclocheilichthys enoplos)* ត្រីព្រួល *(Cirrhinus microlepis)* ត្រីប្រា *(Pangasianodon hypophthalmus)* និង ត្រីត្រសក់ *(Probarbus jullieni)* | 48 |
| លោក លី វុទ្ធី<br>លោក យិន ដារ៉ា<br>លោក ភីធ័រ ឌីហ្គិន | ការគ្រប់គ្រងនេសាទទឹកសាបនៅកម្ពុជា:<br>គោលការណ៍ច្បាប់ និងការអនុវត្តជាក់ស្តែង | 77 |
| លោក ជា វណ្ណារ៉េន<br>លោក សៀន គិន | ការថែរក្សាធនធានជលផលក្នុងអន្លង់នានាតាមដងទន្លេមេគង្គ ក្នុងខេត្តក្រចេះ និង ស្ទឹងត្រែង | 99 |
| លោក ទ្រឿង រដ្ឋ | ការនេសាទដោយឧបករណ៍នេសាទឆ្មុយ នៅស្ទឹងសង្កែ ខេត្តបាត់ដំបង | 110 |
| លោក ឆេង វិបុលរិទ្ធ | ការវាយតំលៃឡូត៍លេខ ៥ ក្នុងខេត្តសៀមរាប បន្ទាប់ពីត្រូវបានលុបនៅឆ្នាំ១៩៩៨ | 124 |
| លោក ឈួន គិមឈា | ចំណេះដឹងរបស់អ្នកនេសាទស្តីពីការធ្វើចរាចរ របស់ត្រីប្រាសំខាន់ៗ *(Pangasius)* ៣ ប្រភេទ នៅក្នុងទន្លេមេគង្គ | 135 |
| លោក ចាន់ សុខហេង | ការធ្វើចរាចររបស់ត្រីរៀល *(Henicorhynchus siamensis)* នៅក្នុងទន្លេមេគង្គ | 149 |
| លោក ស៊ឹម វិរយៈ<br>លោក ថាយ សុមុនី<br>អ្នកស្រី កែវ សុវណ្ណារី<br>លោក ឈួន វន់<br>កញ្ញា ហ្សិតប៊ូនសាង<br>លោក យេនី | ការសិក្សាអំពីការផ្គត់ផ្គង់កូនត្រីពូជក្នុងខេត្តកណ្ដាល តាកែវ និង ព្រៃវែង នៅតំបន់ដីសណ្ដទន្លេមេគង្គនៃប្រទេសកម្ពុជា | 154 |

# Content


| | | |
|---|---|---|
| Preface | | ii |
| Content | | iv |
| Nao Thuok<br>Nicolaas van Zalinge | Challenges in managing Cambodia's inland fisheries. How can we meet them? | 10 |
| Nam Sokleang | Mekong River flow data analysis | 23 |
| Ngor Peng Bun | Dai fishery in the Tonle Sap River of Phnom Penh and Kandal province (including a Review of the Census Data of 1996-97) | 38 |
| Srun Phallavan<br>Ngor Peng Bun | The dry season migration pattern of five Mekong fish species: Riel *(Henicorhynchus spp.)*, Chhkok *(Cyclocheilichthys enoplos)*, Pruol *(Cirrhinus microlepis)*, Pra *(Pangasianodon hypophthalmus)* and Trasork *(Probarbus jullieni)* | 61 |
| Ly Vuthy<br>Yin Dara<br>Peter Degen | The management of the freshwater capture fisheries in Cambodia: legal principles and field implementation | 90 |
| Chea Vannaren<br>Sean Kin | Fisheries preservation in the Mekong River pools in Stung Treng and Kratie provinces | 105 |
| Troeung Rot | Uy fishery in the Sangke River, Battambang province, Cambodia | 117 |
| Chheng Vibolrith | Evaluation of ex-fishing lot no. 5 after its abolishment in 1988, Siem Reap province, Cambodia | 129 |
| Chhuon Kim Chhea | Fisher's knowledge about migration patterns of three important *Pangasius* catfish species in the Mekong mainstream | 141 |
| Chan Sokheng | The migration pattern of Trey Riel, *Henicorhynchus siamensis*, in the Mekong mainstream | 151 |
| Sem Viriyak<br>Thay Somony<br>Keo Sovannary<br>Chhoun Von<br>Setboonsarng<br>Jeney | An overview of fish seed supply in three provinces of the Mekong delta region of Cambodia | 164 |

# I

# កិច្ចខិតខំប្រឹងប្រែងគ្រប់គ្រងនេសាទទឹកសាបកម្ពុជា តើយើងអាចសំរេចបែបណា?

ដោយ

លោក **ណៅ ធួក**[1] និង លោក **នីកូឡាស វ៉ាន់ ហ្សាលីង**[2]

1. ប្រធាននាយកដ្ឋានជលផល និង ជានាយកគ្រោងការជាតិគ្រប់គ្រងនេសាទទឹកសាបកម្ពុជា
2. ប្រធានទីប្រឹក្សាបច្ចេកទេស គ្រោងការគ្រប់គ្រងនេសាទទឹកសាបកម្ពុជា

## ១. សេចក្តីផ្តើម

ការស្រាវជ្រាវនេសាទត្រូវបានរៀបចំអនុវត្តនៅកម្ពុជា ដើម្បីជួយបង្កើតឡើង និងអនុវត្តគោលនយោបាយគ្រប់គ្រងនេសាទ ក្នុងន័យធានាអោយមាននិរន្តរភាពក្នុងការប្រើប្រាស់ធនធាន និងជួយជាប្រយោជន៍ពិសេសចំពោះប្រជាជនក្រីក្រនៅតាមជនបទ។

ការស្រាវជ្រាវ បានចង្អុលបង្ហាញយ៉ាងច្បាស់ទៀតថា ផលនេសាទទឹកសាបកម្ពុជាបានទទួលចំណាត់ថ្នាក់លេខ៤ ក្នុងពិភពលោក ដែលក្នុងមួយឆ្នាំៗអាចមានបរិមាណពី ៣០០.០០០ តោន ទៅ ៤០០.០០០ តោន។ ផលចាប់នេះ អាចនឹងមានបរិមាណលើសពីនេះទៅទៀត បើតាមការប៉ាន់ប្រមាណ។

ការស្ទង់មតិក៏បានបង្ហាញដែរថា ត្រីមានសារៈសំខាន់ក្នុងការធានាសុវត្ថិភាពស្បៀងអាហាររបស់ប្រជាជន ជាពិសេសប្រជាពលរដ្ឋនៅតាមជនបទ ដែលមានប្រមាណ ៨៥% នៃប្រជាជនទូទាំងប្រទេស។ ការស្រាវជ្រាវសេដ្ឋកិច្ចសង្គម (១៩៩៥-៩៦) ទៅលើចំនួនប្រជាជន ៤.២ លាននាក់ ដែលរស់នៅភាគកណ្តាលនៃប្រទេសកម្ពុជា បានបញ្ជាក់អោយឃើញថា ប្រជាជនម្នាក់ហូបត្រី ៦៧ គ.ក្រ/ក្នុង១ឆ្នាំ។

ប្រទេសកម្ពុជាសំបូរត្រី ដោយសារមានទំនាបលិចទឹកប្រចាំឆ្នាំដ៏ធំនៅតាមបណ្តោយទន្លេមេគង្គ ជុំវិញបឹងទន្លេសាប ដងទន្លេសាប និង ទំនាបលិចទឹកប៉ែកព្សសាន និងខាងត្បូងរាជធានីភ្នំពេញ។ ទំនាបលិចទឹកទាំងនោះ ដូចជា ទំនាបព្រៃលិចទឹក ជាទីជំរកដ៏សំខាន់សំរាប់អោយមច្ឆាជាតិពងកូន (រូបទី១.១ និងទី១.២ ទំព័រ១៦)។ ការធ្វើចរាចរដ៏ច្រើនរបស់ត្រីតាមរដូវកាល ប្រព្រឹត្តិទៅរវាងទំនាបលិចទឹកទាំងនេះ និងទីជំរកពងកូននៅក្នុងទន្លេមេគង្គ បណ្តាទន្លេនៅប៉ែកព្សសាននៃប្រទេសកម្ពុជា និងភាគខាងត្បូងនៃប្រទេសឡាវ។

អាស្រ័យដោយមានកង្វះខាតភស្តុតាងពីមុនមក ប៉ុន្តែគេបានសង្កេតឃើញមានការថយចុះនៃផលនេសាទនៃប្រភេទត្រីធ្វើចរាចរច្រើន និងរីកលូតលាស់យឺតដោយសារកំណើនយ៉ាងខ្លាំងនៃការនេសាទហួសកំរិត។ ផ្ទុយទៅវិញ ប្រភេទត្រីតូចដែលលូតលាស់ឆាប់ដូចជា ត្រីរៀល *(Henicorhynchus sp.)* នៅរក្សាលំនឹងក្នុងទិន្នន័យផលនេសាទ និងមានសមាសភាគច្រើនក្នុងផលនេសាទជានិច្ច។

ការធ្វើសារពើភ័ណ្ឌលើផ្ទៃដីរវាងឆ្នាំ១៩៧៣ និងឆ្នាំ១៩៩៣ បានបង្ហាញថា ព្រៃលិចទឹកបានបាត់បង់ចំនួន ១/៣ ដែលអាចជាហេតុធ្វើអោយមានការថយចុះនៃផលិតភាពធនធានមច្ឆាជាតិ។ នេះក៏អាចបណ្តាលមកពីទំនាបលិចទឹកមានការ

ថយចុះ ដោយសារទំនប់ជាច្រើនត្រូវបានសាងសង់ឡើង ក្នុងគោលបំណងផលិតថាមពលវារីអគ្គិសនី និងប្រព័ន្ធធារាសាស្ត្រ នៅក្នុងអាងទន្លេមេគង្គខាងលើនៃប្រទេសកម្ពុជា (ជាពិសេសនៅប្រទេសចិន) ដែលជាហេតុបណ្តាលអោយកំពស់ទឹកទន្លេមេគង្គខាងលើនៃប្រទេសកម្ពុជាទាបជាង បើប្រៀបធៀបកាលពីពេលមុន។ លើសពីនេះទៅទៀត ចំនួនប្រជាជនបានកើនឡើង ឯឱកាសស្វែងរកអាជីពនៅមានកំរិតទាប និងសិទ្ធិតាមផ្លូវច្បាប់ក្នុងការកាន់កាប់ដីធ្លី នៅពុំទាន់អនុវត្តអោយបានល្អនៅឡើយ ដែលជាហេតុធ្វើអោយព្រៃលិចទឹកដែលជាជំរកត្រីពងកូន ជាពិសេសនៅតំបន់ទំនាបភាគខាងត្បូងនៃរាជធានីភ្នំពេញ ត្រូវបានបាត់បង់យ៉ាងច្រើន។

សិទ្ធិក្នុងការធ្វើនេសាទក្នុងដែននេសាទសំខាន់ៗ ត្រូវបានកំណត់អស់រយៈកាលជាងមួយសតវត្សមកហើយ តាមរយៈប្រព័ន្ធនៃការជួលដែននេសាទរបស់រដ្ឋាភិបាល ទៅអោយអាជីវករឡូត៍នេសាទជាច្រើន ដែលមានទំហំយ៉ាងធំលាតសន្ធឹងក្នុងតំបន់ទំនាបព្រៃលិចទឹក ដែលជាទីជំរកយ៉ាងសំខាន់សំរាប់ស្វែងរកចំណី និងពងកូនរបស់ត្រីជាច្រើនប្រភេទ។ ឡូត៍នេសាទទាំងនេះបានជួយផ្តល់នូវការការពារទីជំរកត្រីបានខ្លះ។ ដោយសាររចនាសម្ព័ន្ធគ្រប់គ្រងនៅខ្សោយបានបណ្តាលអោយកើតមានទំនាស់ជាច្រើនជុំវិញសិទ្ធិធ្វើនេសាទ រវាងអ្នកឡូត៍នេសាទ និងបណ្តាអ្នកនេសាទនៅជុំវិញឡូត៍ និងសហគមន៍កសិករ ហើយបរិយាកាសខាងនយោបាយក៏ហាក់ដូចជាពុំទាន់បានផ្តល់លក្ខណៈងាយស្រួល ដល់ការដោះស្រាយបញ្ហាទំនាស់តាមបែបសហការគ្រប់គ្រងនៅឡើយ។

ដើម្បីឈានទៅរកជោគជ័យខ្លះៗចំពោះដំណោះស្រាយបញ្ហាទាំងនេះ រដ្ឋាភិបាល និងបណ្តាអ្នកផ្តល់អំណោយ ចាំបាច់ត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាដែលជះឥទ្ធិពលមិនល្អដល់វិស័យជលផល ដូចជាត្រីនៅតែជាសុវត្ថិភាពស្បៀងអាហារដ៏សំខាន់ដែលប្រជាជនត្រូវការចាំបាច់ (ជាពិសេសនៅកម្ពុជា ក៏ដូចជានៅតំបន់ខ្លះនៃប្រទេសឡាវ និង ប្រទេសវៀតណាម)។ លើសពីនេះទៅទៀត ជលផលកម្ពុជាអាចជួយទ្រទ្រង់សេដ្ឋកិច្ចជាតិយ៉ាងខ្លាំងក្លាក្នុងពេលអនាគត ដោយសារធនធានមច្ឆាជាតិនៅបណ្តាប្រទេសជិតខាងបានធ្លាក់ចុះជាបន្តបន្ទាប់ ប៉ុន្តែតំរូវការត្រីសាច់ ជាអាហាររបស់ប្រជាជនចេះតែកើនឡើងជាលំដាប់។

ជារួមធនធានមច្ឆាជាតិ ស្ថិតនៅក្រោមការគំរាមកំហែង ប៉ុន្តែភាគច្រើនស្ថិតនៅក្នុងស្ថានភាពល្អ។ លើសពីនោះទន្លេមេគង្គនៅកម្ពុជា នៅតែហូរដោយសេរី (ទន្លេសាប) ឯទីជំរករបស់ត្រីនៅតំបន់ទំនាបលិចទឹក នៅមានទំហំធំ និងមានលក្ខណៈល្អនៅឡើយ។ ផលនេសាទអាចផ្តល់អាជីពដល់ប្រជាជនរាប់លាននាក់ និងបានផ្តល់ត្រីសាច់ ជាសុវត្ថិភាពស្បៀងអាហារដល់ប្រជាជាតិទាំងមូល។ តែទោះជាយ៉ាងណាក្តី អ្វីដែលជាបញ្ហាប្រឈមមុខចំពោះជលផលកម្ពុជា គឺសេចក្តីត្រូវការត្រីសាច់យ៉ាងខ្លាំងជាទីបំផុតក្នុងពេលអនាគត។ យើងចាំបាច់ត្រូវធ្វើអោយមានតុល្យភាពរវាងសេចក្តីត្រូវការក្នុងប្រទេស នាំចេញទៅក្រៅប្រទេស និងតំរូវការរក្សាធនធានធម្មជាតិ និង តំរូវការផលិតថាមពលវារីអគ្គិសនី ទំនប់ធារាសាស្ត្រ និងបំរែបំរួលបរិស្ថាន។ ទាំងនេះគឺជាជំរើស និងការសំរេចចិត្តជាពិសេសដោយរដ្ឋាភិបាល ក្នុងការកំណត់អនាគតប្រទេសជាតិប្រជាជន និងអនាគតនៃធនធានធម្មជាតិ។

## ២. កិច្ចខិតខំប្រឹងប្រែងគ្រប់គ្រងធនធានជលផល

បញ្ហាចំបងដែលជះឥទ្ធិពលមិនល្អដល់ជលផលកម្ពុជា ត្រូវបានចង្អុលបង្ហាញនៅលើផែនទី (រូបទី១.៣ ទំព័រ១៧)។ យើងចែកបញ្ហាទាំងនេះជាពីរផ្នែក : (១) បញ្ហាកើតឡើងមិនស្ថិតនៅក្នុងការគ្រប់គ្រងដោយផ្ទាល់របស់នាយកដ្ឋានជលផល